# បដិមាហរិហរៈក្នុងសិល្បៈខ្មែរ

## តើហរិហរៈជាអ្វី?

**ហរិហរៈ** ជាភាសាសំស្ក្រឹតមានន័យសំដៅលើការរួមគ្នាពាក់កណ្ដាលរវាងព្រះវិស្ណុ និងព្រះសិវៈ។ "**ហរិ**" ជាឈ្មោះមួយក្នុងចំណោមឈ្មោះដ៏ច្រើនរបស់ព្រះវិស្ណុ ដែលមានភាគតួខ្លួននៅផ្នែកខាងឆ្វេង។ ចំណែក "**ហរៈ**" ក៏ជាឈ្មោះមួយក្នុងចំណោមឈ្មោះជាច្រើនរបស់ព្រះសិវៈដែរ ដែលមានចំណែកតួខ្លួននៅផ្នែកខាងស្ដាំ។ និយាយជាខ្លីមក**ហរិហរៈ** គឺជាតួអង្គទេពម្នាក់ដែលកើតឡើងពីការផ្សំគ្នាពាក់កណ្ដាលពីព្រះវិស្ណុ និងពាក់កណ្ដាលពីព្រះសិវៈ។ ជាទូទៅ **ហរិហរៈ** មានព្រះកេស១ដែលមួយចំហៀងខាងស្ដាំជាព្រះភ័ក្ត្ររបស់ព្រះសិវៈ និងមួយចំហៀងខាងឆ្វេងជាព្រះភ័ក្ត្ររបស់ព្រះវិស្ណុ។ ចំណែកព្រះហស្តមានចំនួន៤ គឺ២ខាងស្ដាំជាព្រះហស្តរបស់ព្រះសិវៈដែលមានកាន់កេតណភណ្ឌ២ (ខាងលើកាន់ត្រីសូល និងខាងក្រោមកាន់ស្គរ(?) ហើយព្រះហស្តខាងឆ្វេង២ជារបស់ព្រះវិស្ណុមានកាន់កេតណភណ្ឌ២ដែរ (ខាងលើកាន់កងចក្រ និងខាងក្រោមកាន់ដំបង)។ យើងអាចសំគាល់បានថាខាងស្ដាំជាតួអង្គព្រះសិវៈដោយសារការតុបតែងមុខ គឺដូនកាលមានពុកមាត់ និងភ្នែកទី៣ពាក់កណ្ដាលបញ្ឈរនៅលើថ្ងាស និងមានរចនាម៉ូតក្នុងសក់ជាម្កុដ (ជទមកុដ) ម្យ៉ាងស្អាតជាមួយនឹងចំណិតព្រះខែផ្ដេក (ជួនកាលពាក់កណ្ដាល) ទៀតផង គឺផ្ទុយស្រឡះពីព្រះភ័ក្ត្ររបស់ព្រះវិស្ណុដែលពុំមានតុបតែងលម្អអ្វីបន្តិចសោះ មានតែក្នុងសក់រាងជាស៊ីឡាំងត្រង់ ឬហៅថាកិរីដមកុដ។

ជាទូទៅ បដិមាសាស្ត្របែបសំយោគរវាងទេពពីរ ជាលទ្ធិដ៏ពេញនិយមរបស់ខ្មែរនាសម័យមុនអង្គរ ពិសេសយើងឃើញមានតាំងពីរចនាបថភ្នំដាមកម្ទេះ។ **ហរិហរៈ** គឺមានលក្ខណៈដូចគ្នាទៅនឹងព្រះនាងទុគ៌ាដែលទទួលនូវកំលាំងរួមបញ្ចូលពីទេពផ្សេងៗ ដើម្បីផ្តុំជាថាមពលដ៏មហាសាលមួយក្នុងតួនាទីបង្កើត និងការពារ និងតួនាទីបំផ្លាញអ្វីមួយដែលជាភារៈអាក្រក់នៅក្នុងលោក។ ក្នុងសិល្បៈឥណ្ឌា **ហរិហរៈ** គឺជាការលាយបញ្ចូលគ្នារវាងព្រះសិវៈ និងព្រះវិស្ណុ ដែលគេស្គាល់ថា **សន្ករនារាយណ** ជាទម្រង់កំពូលនៃទេពដែលមានឆ្លាក់នៅតាមជញ្ជាំងប្រាសាទមួយចំនួន ក្នុងប្រទេសឥណ្ឌានាសតវត្សទី៦មក

**អត្ថបទដោយ៖ លោក សុខ កែវ សុវណ្ណារ៉ា**

ម៉្វេះ[១]។ ចំណែកក្នុងសិល្បៈខ្មែរ **ហរិហរៈ** ពុំឃើញមានក្នុងចម្លាក់ក្រឡោតទាប ឬក្រឡោតខ្ពស់ទេ។ យើងឃើញមានតែបដិមាជាទូទៅធ្វើអំពីថ្ម ពុំមានធ្វើអំពីលោហៈទេ។ បដិមាហរិហរៈក៏មានចាប់ពីជិតពាក់កណ្ដាលសតវត្សទី៦ (រចនាបថភ្នំដា) មកដែរ គឺបដិមាហរិហរៈនៅអាស្រមមហាឫស្សី (រូបលេខ១)[២]។ ការគោរពលើ **ហរិហរៈ** គឺជាលិទ្ធិពេញនិយមមួយក្នុងសង្គមខ្មែរនាសម័យមុនអង្គរ ហើយបានបាត់បង់នៅក្នុងសម័យអង្គរ[៣]។ បដិមាហរិហរៈមួយផ្សេងទៀតរកឃើញនៅបាថេ (រូបលេខ២)[៤] អាចមានអាយុកាលចំណាស់ជាងបដិមាហរិហរៈនៅអាស្រមមហាឫស្សី បើពិនិត្យមើលអំពីរូបរាង និងជំហររបស់បដិមានោះ។ ក្រៅពីនេះព្រះកេសហរិហរៈ (រូបលេខ៣)[៥] មួយផ្សេងទៀតក៏បានរកឃើញ ប្រហែលដោយលោក E. Aymonier នៅតំបន់ព្រៃកប្បាស (ព្រះកេសនេះត្រូវបានគេយកទៅតាំងនៅសារមន្ទីរ ហើយដង្ខួននៅសារមន្ទីរជាតិភ្នំពេញ ក្រោយមកបានគេបានស្នើសុំយកមកភ្ជាប់គ្នាវិញ រួចដាក់តាំងក្នុងសារមន្ទីរជាតិភ្នំពេញសព្វថ្ងៃ)។ បើធ្វើការប្រៀបធៀបផ្ទៃមុខ និងការតុបតែងលម្អជាមួយនឹងបដិមាហរិហរៈនៅអាស្រមមហាឫស្សីឃើញថា មានលក្ខណៈដូចគ្នាទៅនឹងអ្វីដែលគេស្គាល់ថារចនាបថភ្នំដាដែរ។ មកដល់សតវត្សទី៧ ការគោរព និងកសាងបដិមាហរិហរៈនៅតែបន្ត តួយ៉ាងដូចជាបដិមាហរិហរៈ (រូបលេខ៤)[៦] នៅប្រាសាទតួខាងជើងលេខ១០នៃក្រុមខាងជើងប្រាសាទសំបូរព្រៃគុក (N10) គឺជាបដិមាហរិហរៈធ្វើអំពីថ្មភក់ កំពស់១៦៦សង់ទីម៉ែត្រ។ បដិមាហរិហរៈក្នុងសារមន្ទីរជាតិអង្គរដែលរកឃើញក្នុងខេត្តកំពង់ចាម (រូបលេខ៥) មានលក្ខណៈ និងរូបរាងដូចគ្នាទៅនឹងបដិមាដទៃទៀតដែលស្ថិតនៅក្នុងរចនាបថព្រៃក្មេង (៦៣៥គ.សដល់៧០០គ.ស)។ នាចុងសតវត្សទី៧ដើមសតវត្សទី៨ ហរិហរៈហាក់ដូចជាត្រូវបានគេគោរពកាន់តែច្រើន ដោយសារយើងឃើញមានបដិមាទេពនេះមានចំនួនច្រើននៅតាមប្រាសាទនានា ដូចជាហរិហរៈប្រាសាទអណ្ដែត

---

[១] Alice Boner 1990: 89-95

[២] Helen I. Jessup and Thierry Zéphir 1997: 164

[៣] Helen I. Jessup, 2004: 32-33

[៤] Ha Du Canh and James C.M. khoo 2003: 140

[៥] Pierre Baptise and Thierry Zéphir 2008: 59

[៦] Helen I. Jessup and Thierry Zéphir 1997: 133

(រូបលេខ៦) (ដែលគេឱ្យជារចនាបថមួយអន្តរកាលរវាងរចនាបថព្រៃក្មេង និងរចនាបថកំពង់ព្រះ) ហរិហរៈត្រពាំងផុង(I) (រូបលេខ៧) និងហរិហរៈរកឃើញនៅខេត្តកំពង់ចាម។ រចនាបថមួយដែលមាន រយៈពេលវែងស្មើរតែពេញ១សតវត្សក្នុងសិល្បៈខ្មែរ គឺកំពង់ព្រះ (៧០៦គ.សដល់៨០០គ.ស) ក៏មានបដិមាហរិហរៈដែរ ដូចជាហរិហរៈត្រពាំងផុង(II) (រូបលេខ៨)[៧]ហរិហរៈនៅប្រាសាទភូមិប្រាសាទ ហរិហរៈរកឃើញនៅខេត្តកំពង់ចាមមួយផ្សេងទៀត។ មកដល់សម័យអង្គរជាសម័យកាលដែលមានការរីកចំរើនខាងសំណង់ស្ថាប័ត្យកម្មប្រាសាទ និងបដិមាសាស្ត្រនៃអាណាចក្រខ្មែរ តែការបង្ហាញលើលទ្ធិហរិហរៈហាក់ដូចជាមិនសូវមានការពេញនិយម ពោលយើងឃើញមានបដិមាហរិហរៈតិចតួចណាស់។ ព្រះកេសហរិហរៈ (រូបលេខ៩) មួយសព្វថ្ងៃតាំងនៅសារមន្ទីរ Guimet ត្រូវបានគេរកឃើញ ហើយសន្និដ្ឋានថាស្ថិតក្នុងរចនាបថបាខែង (៨៩៣គ.សដល់៩២៥គ.ស)។ បដិមាហរិហរៈដែលយើងឃើញក្នុងសិល្បៈខ្មែរចុងក្រោយគេ គឺជាព្រះកេសបដិមាហរិហរៈ (រូបលេខ១០)[៨] ក្នុងរចនាបថប្រែរូប (៩៤៤គ.សដល់៩៦៨គ.ស)។

ក្រៅអំពីបដិមា យើងក៏ឃើញមានសេចក្ដីរៀបរាប់ផងដែរ អំពីទេពហរិហរៈនៅក្នុងសិលាចារឹកខ្មែរបុរាណ។ យ៉ាងហោចណាស់យើងឃើញមានពាក្យហរិហរៈ៤ដងក្នុងសិលាចារឹកនាដើមសតវត្សទី១០ដល់សតវត្សទី១៣ ដែលសិលាចារឹកទាំងនោះជាទូទៅនិយាយអំពីឈ្មោះទីតាំងកន្លែងមួយហៅថា **ហរិហរល័យ**។ **ហរិហរល័យ** ជារាជធានីបុរាណមួយដែលគេគិតថាជាបុរីដែលស្ថាបនាឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២ (៨០២គសដល់៨៥០គ.ស) ហើយស្ថិតនៅតំបន់រលួស(សៀមរាប)សព្វថ្ងៃ ឬជាឈ្មោះពិតរបស់ប្រាសាទលលៃ[៩]។ យើងពុំឃើញមានការបរិយាយអំពីហរិហរល័យក្នុងសិលាចារឹកសតវត្សទី៩ ឬក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២ទេ គឺគេដឹងតាមរយៈសិលាចារឹកសតវត្សទី១០ ទី១១ និងទី១៣។ សិលាចារឹកប្រាសាទស្រង៉ែ K.933[១០] មានកាលបរិច្ឆេទឆ្នាំ១០១៣គ.ស ក្នុង

[៧] Helen I. Jessup and Thierry Zéphir 1997: 144

[៨] Emma C. Bunker and Douglas Latchford 2004:180-181

[៩] Savarou Pov 2000: 547

[១០] G. Cœdès 1952: 48

រាជ្យព្រះបាទសូរ្យវរ្ម័នទី១ មួយផ្នែកនិយាយរំលឹកអំពីការកសាងអាស្រមមួយដល់ព្រះរាជគ្រូរបស់ព្រះបាទជ័យវរ្ម័នទី៥ នៅហរិហរៈល័យនាឆ្នាំ៩០០សក (៩៧៨គស)។ សិលាចារឹកប្រាសាទស្វាយព្រាហ្ម K.848 និយាយអំពីព្រះរាជបញ្ជាមួយនៅតំបន់ហរិហរៈ។ សិលាចារឹកមួយទៀតនៅប្រាសាទស្តុកកក់ធំ[១១] K.235 (១០៥២គ.ស) ចារដោយព្រះរាជគ្រូម្នាក់រៀបរាប់អំពីគ្រួសាររបស់គាត់ ដែលបានបម្រើស្តេចតាំងពីរាជ្យព្រះបាទជ័យវរ្ម័នទី២មក នៅតំបន់ហរិហរៈល័យ។

សរុបមកយើងឃើញថាការគោរពលើបដិមា ឬលទ្ធិហរិហរៈរបស់ខ្មែរ គឺប្រហាក់ប្រហែលគ្នាទៅនឹងឥណ្ឌាតាំងពីសតវត្សទី៦មក ហើយលទ្ធិនេះទៀតសោត គឺពេញនិយមនៅក្នុងសម័យមុនអង្គរ ពិសេសសតវត្សទី៧ និងទី៨។ តាមរយៈព្រះកេសពីរដែលមួយអាចនៅក្នុងរចនាបថបាខែង និងមួយទៀតក្នុងរចនាបថប្រែរូប នេះសបញ្ជាក់ឱ្យឃើញថាលទ្ធិហរិហរៈនៅមានការគោរពរហូតដល់ពាក់កណ្តាលសតវត្សទី១០ មកដល់សតវត្សទី១១ យើងពុំឃើញមានការគោរលទ្ធិហរិហរៈបន្តទៀតនោះទេ។



រូបលេខ២១៖ ហរិហរៈ អាស្រមមហាឫស្សី



រូបលេខ២២៖ ហរិហរៈនៅបាថេ



រូបលេខ២៣៖ ព្រះកេសហរិហរៈ ព្រៃកប្បាស

[១១] Chhany Sak-Humphry 2005:106



រូបលេខ៤៖ ហរិហរៈ សំបូរព្រៃគុក



រូបលេខ៥៖ ហរិហរៈកំពង់ចាម (ប្រភព៖សារមន្ទីរជាតិអង្គរ)



រូបលេខ៦៖ ហរិហរៈ ប្រាសាទអណ្ដែត



រូបលេខ៧ ហរិហរៈត្រពាំងផុងI



រូបលេខ៨៖ ហរិហរៈ ត្រពាំងផុង II (ប្រភព៖ BEFEO)



រូបលេខ៩៖ ហរិហរៈ (រចនាបថបាខែង?)



រូបលេខ១០៖ ហរិហរៈ (រចនាបថប្រែរូប?)

## ឯកសារយោង


Alice Boner.
*1909. Principles of Composition in Hindu Sculpture: Cave Temple Period*, Motilal Banarsidass, pp.89-95.

Helen I. Jessup and Thierry Zéphir.
*1997. Sculptures of Angkor and Ancient Cambodia*, New York, p.164.

Helen Ibbitson Jessup.
*2004. Art and Architecture of Cambodia*, Singapore, pp 32-33

Ha Du Canh and James C.M. khoo.
2003. Some Observation on Religious Sculptures in the Mekong Delta, in *Art and Archaeology of Fu Nan*, *The Southeast Asian Ceramic Society*, Bangkok, p.140.

Pierre Baptise and Thierry Zéphir.
2008. *L'Art Khmer dans les collections du muse Guimet*, Paris, p. 59.

Helen I. Jessup and Thierry Zéphir.
1997. *Sculptures of Angkor and Ancient Cambodia*, New York, p133.

Helen I. Jessup and Thierry Zéphir.
1997. *Sculptures of Angkor and Ancient Cambodia*, New York, p144.

Emma C. Bunker and Douglas Latchford.
2004, *Adoration and Glory-The Golden Age of Khmer Art*, Art Media Resources, Chicago, pp.180-181.

Savarou Pov.
*2000. Dictionary Old Khmer English and French*, Paris, p547.

G. Cœdès.
*1952. Inscription du Cambodge*, Tome IV, Paris, p48.

Chhany Sak-Humphry.
2005. *The Sdok Kak Thom Inscription,* The Edition of the Buddhist Institute, p.106